# ល្បែង៖ តម្រៀបកែវជ័រជាក្រុម

**កម្មវិធីសិក្សា៖**

**ចិត្តចលភាព៖** បំណិនចលកតូច (ការហ្វឹកហាត់បង្កើនកម្លាំង សម្របសម្រួលសាច់ដុំដៃ និងភ្នែកសាច់ដុំភ្នែក)

**សិក្សាសង្គម៖** គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងការពេញចិត្តចំពោះសិល្បៈតាមរយៈការបង្កើតរូបភាព៖

**បុរេគណិត៖** រង្វាស់រង្វាល់៖ បញ្ញត្តិស្តីពីរង្វាស់រង្វាល់៖

**រយៈពេល៖** ៣០ នាទី

**ឧបករណ៍៖** កែវជ័រដែកលមានសភាពរឹងបន្តិច រឹងខ្លាំងកាន់តែល្អ ខ្សែអ្វីក៏បានដែរ ដែលមានទំហំតូចល្មម និងកៅស៊ូកង និងអ្វីក៏បានដែរឱ្យតែមានសភាពយឺតៗ។

**គោលបំណង៖ (ចិត្តចលភាព)** ប្រាប់ពីររបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយការធ្វើអ្វីមួយ ឬលេងល្បែង។ បង្ហាញពីរបៀបធ្វើសកម្មភាពទៅតាមទម្រង់ផ្សេងៗនៃសកម្មភាពរួមមួយ។

**(សិក្សាសង្គម)៖** ប្រាប់បានពីការបត់ រោយ ដេរ ត្បាញ សូនរូប គូរ ផាត់ពណ៌ ហែក កាត់ បិទ បត់… និងបង្កើតរូបភាពផ្សេងៗ។

**(បុរេគណិត):** ប្រាប់បានពីបញ្ញត្តិខ្ពស់ និងទាប វែងនិងខ្លី ធ្ងន់និងស្រាល ច្រើននិងតិច មាននិងមិនមាន ពេញនិងកន្លះ…។

**ត្រៀម៖** ធ្វើសម្ភារ១ឬ២ឈុតសម្រាប់បង្ហាញកុមារមុនពេលដែលត្រូវលេងល្បែងសកម្មភាពមួយនេះ។

**សេចក្តីណែនាំ៖**

១. ប្រាប់ក្មេងថាថ្ងៃនេះពួកគេនឹងលេងល្បែងសកម្មភាពមួយដែលមានចំណងជើងថា ល្បែងតម្រៀបកែវជ័រជាក្រុម។

២. ប្រាប់កុមារថាលេងល្បែងសកម្មភាពនេះត្រូវមានសម្ភារអ្វីខ្លះ? សម្ភារមានដូចខាងលើ។

៣. ប្រសិនបើមានពេលច្រើននោះ អាចបង្រៀនកុមារឱ្យចេះពីរបៀបធ្វើវាក៏បាន៖

- ❖ ប្រើកែវជ័ររឹងមួយចំនួន កាន់តែច្រើនកាន់តែល្អ
- ❖ ប្រើខ្សែដែលមានប្រវែងប្រហែលជា ៧០សង់ទីម៉ែត្រ ចំនួន៤ ឬ៥ ក្នុងមួយក្រុម ទៅតាមចំនួនកុមារក្នុងក្រុមនីមួយៗ
- ❖ ខ្សែចងជុំវិញកៅស៊ូ ដែលមានចន្លោះល្មមដូចក្នុងរូប។

៤. បែងចែកកុមារទៅជាក្រុមនីមួយៗដែលមានចំនួន៤ឬ៥នាក់ក្នុងមួយក្រុម

៥.  ពង្រាយកែវជ័រទាំងអស់នៅលើតុមួយ តាមក្រុមនីមួយដែល ចំនួនតាម

រការរបៀបចំរបស់អ្នក។

៦. ឱ្យក្រុមនីមួយៗប្រណាំងគ្នា ដោយតម្រៀបកែវឱ្យបានអស់មុន និងខ្ពស់ជាងគេ

៧. កំណត់នាទីសម្រាប់ការលេងល្បែងនេះដោយបានសមរម្យ

៨. នៅពេលដែលក្រុមណាដែលធ្វើដួល ត្រូវចាប់ផ្តើមម្តងទៀត

ធ្វើបន្តរហូតដល់អស់នាទីដែលបានកំណត់ពីខាងលើ។

៩. កុមារត្រូវទាញខ្សែដែលនៅនឹងដៃរបស់ខ្លួននីមួយៗបន្តិច

ដើម្បីឱ្យបានពន្លាក្នុងការចាប់យកកែវជ័រនោះ ម្តងមួយៗ។

១០. គ្រាន់តែលេងប៉ុណ្ណឹងជាការស្រេច និងប្រាប់កុមារឱ្យជួយរៀបចំកន្លែង ហើយរៀបចំឱ្យរៀបរយ។

**ការប្រែប្រួល៖**

- ល្បែងនេះអាចលេងជាក្រុមដោយប្រកួតប្រជែងក៏បាន ឬលេងធម្មតាក៏បានដែរ។
- ល្បែងនេះអ្នកអាចឱ្យកុមារលេងបែបមួយផ្សេងទៀតក៏បានដែរ ដូចជា៖

  ១. ក្នុងក្រុមនីមួយៗត្រូវសហការគ្នាចាប់កែវជ័រមកផ្គុំជាសសរដែលមានកម្ពស់ និងត្រូវតែមិនដួលទៀតផង។

២. អ្នកត្រូវកំណត់នាទីក្នុងការល្បែងសកម្មភាពនេះដូចខាងលើដែរ។

៣. ប្រសិនបើគ្រប់នាទីហើយ ត្រូវប្រាប់ឱ្យកុមារទាំងអស់ក្រុមឈប់ និងរាប់កែវ ហើយនិងខ្ពស់ជាងគេ គឺក្លាយជាក្រុមដែលឈ្នះតែម្តង។

- វិធីមួយទៀត៖ អ្នកអាចលេងជាបែបកែវពណ៌វិញក៏បានដែរ គឺចាប់គូកែវដែលមានពណ៌ដូចគ្នា៖

១. ដាក់កែវជ័រដែលមានពណ៌ច្រើន ហើយដែលមានពណ៌ដូចគ្នា២ ២ មានន័យពណ៌ជាគូៗតែម្តង។

២. កុមារក្នុងក្រុមនីមួយៗត្រូវប្រណាំងគ្នា រៀបឬចាប់កែវដែលមានពណ៌ដូចគ្នាដាក់គ្របពីលើគ្នា ឱ្យអស់ មុនពេលដល់ពេលវេលាដែលបានកំណត់។

៣. កំណាត់១ ឬ២ នាទីទៅតាមចំនួនកែវជ័រដែលមានសម្រាប់ក្រុមនីមួយៗ។

៤. ត្រូវប្រើខ្សែដែលបានធ្វើរួចនោះតែប៉ុណ្ណោះ មិនអាចចាប់ដោយប្រើដៃផ្ទាល់បាននោះទេ។

៥. លេងបែបហ្នឹងជាការស្រេចនៅក្នុងការលេងល្បែងសកម្មភាពមួយនេះ។